**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព | ចូលរួម | លទ្ធផល | សហគមន៍ | សង្ឃឹម



ជំរាបមាតាបិតា/អាណាព្យាបាល,

សូមស្វាគមន៍ត្រីមាសទីពក្រោយពីបានរីករាយនឹងធាតុអាកាសដ៏ស្រស់បំព្រងនៅរយៈពេលវិស្សមកាល!សាលាមានកម្មវិធីនិងការធ្វើដំណើរសិក្សាដ៏ល្អៗនៅត្រីមាសទីពនេះ,សូមយកចិត្តទុកដាក់មើលក្នុងប័ណ្ណព័ត៌មានប្រចាំថ្នាក់សំរាប់ត្រីមាសនេះដែលបានផ្តល់ឲ្យកុមារនៅសប្តាហ៍មុន។ខ្ញុំសង្ឃឹមថាមាតាបិតា/អាណាព្យាបាលក៏បានមករួមក្នុងកិច្ចសម្ភាសន៍នៅសប្តាហ៍មុន,តែបើលោកអ្នកមិនបានមកទេ,សូមទាក់ទងនឹងគ្រូរបស់កុមារដើម្បីមកជួបនៅថ្ងៃក្រោយ,ឬគ្រាន់តែនិយាយតាមទូរស័ព្ទ។

*កំណត់ប្រចាំថ្ងៃ: 17/7/2023*
១៨/៧: កម្មវិធីឆ្លៃស្និទ្ធស្នាលៈសាខាខាងលិច
២៤/៧: សិស្សពីរនាក់មកធ្វើការដកស្រង់បទពិសោធន៍នៅសាលាយើង
STOMP កម្មវិធីរៀនរាំនៅសាខាខាងលិច
២៥/៧: STOMP កម្មវិធីរៀនរាំនៅសាខាវ៉ាល្លី
កម្មវិធីឆ្លៃស្និទ្ធស្នាលៈសាខាខាងលិច
៣១/៧: កិច្ចប្រជុំនៃក្រុមប្រឹក្សាសាលានៅម៉ោង៦:០០ល្ងាច
០១/៨: ថ្នាក់ទី៣/៤ធ្វើដំណើរសិក្សានៅសាលាវូតលី
កម្មវិធីឆ្លៃស្និទ្ធស្នាលៈសាខាខាងលិច

## ដំណឹងបុគ្គលិកសាលា:

ដូចបានជំរាបជូនពីលើកមុនមកថា,Mrs Otenstein កំពុងឈប់សំរាកហូតដល់អស់ត្រីមាទីពនេះ,តែ Mrs Edmondson & Mrs Dounis នឹងបង្រៀនជំនួសសប្តាហ៍ម្នាក់។គ្រូទាំងពីរមានការពិសោធន៍ដ៏បរិបូណ៌ហើយបានស្គាល់កុមារក្នុងសាលាយ៉ាងច្បាស់លាស់។ខ្ញុំផ្ទាល់ក៏នឹងសំរាកចំនួន៥ខែចាប់ពីថ្ងៃទី៧ខែសីហារហូតដល់ចុងឆ្នាំនេះ។Mrs Harry នឹងជានាយកបណ្តោះអាសន្ន,ហើយ Mrs Morgan នឹងជាអគ្គនាយកបណ្តោះអាសន្ននៅពេលអវត្តមានរបស់ខ្ញុំ។ខ្ញុំនឹងទៅប្រទេសអង់គ្លេសដើម្បីស្វាគមន៍ចៅទីពីររបស់ខ្ញុំ,ហើយជួយមើលកូនស្រីទាំងពីររបស់កូនស្រីខ្ញុំ។ខ្ញុំក៏នឹងធ្វើដំណើរទេសចរណ៍នៅតំបន់ដាច់ស្រយោយលនៃប្រទេសអូស្ត្រាលីដោយការ៉ាវ៉ែន(caravan)ជាមួយនឹងប្តីខ្ញុំ។Mrs Wirrick នឹងសំរាកចំនួន៨ថ្ងៃចាប់ពីថ្ងៃទី ២៥ដល់២៨ខែកក្កដា,Mr Muscat នឹងសំរាកក្នុងក្របខ័ណ្ឌសេវាកម្មយូរឆ្នាំចាប់ពី ថ្ងៃទី២៨/៨ រហូតដល់ចុងត្រីមាសទី៣,ហើយនឹងបានជំនួសដោយ Mrs Edmondson. ទីបំផុត Ms Law នឹងសំរាកចាប់ពីថ្ងៃទី១១ ខែ កញ្ញាដល់ទី២០ ខែតុលាតាមរយៈក្របខ័ណ្ឌបានធ្វើការយូរឆ្នាំ។

## ការត្រឡប់មកវិញនៃក្រុមបង្រៀនរាំ STOMP ឆ្នាំ ២០២៣:

យើងខំបានចាត់ចែងសេវាកម្មចំពោះក្រុមហ៊ុនបង្រៀនរាំក្នុងតំបន់យើង STOMP មកធ្វើការប្រចាំសប្តាហ៍ជាមួយនឹងកុមារព្រមជាមួយនឹងបុគ្គលិកសាលាដើម្បីរៀនរាំហើយក៏ដើម្បីធ្វើឲ្យរាត្រីសិល្បៈនៃសាលាយើងដែលនឹងប្រព្រឹត្តទ្បើងនៅថ្ងៃព្រហស្បតិ៍ ទី១៤/៩ នៅមហាសាលស្ត្រីងវ៉េលឲ្យបានល្អបំផុត។ក្រុមនេះនឹងជួយផ្គត់ផ្គង់ប្រធានបទ,ទម្រង់របាំ,គំនិតពីសម្លៀកបំពាក់ហើយធ្វើការជាមួយនឹងកុមារដើម្បីឲ្យតួនាទីរបស់ពួកគេបានល្អឥតខ្ចោះ,ជួយបង្កើតទំនុកចិត្តនិងការយល់ដឹងពីខ្លួនឯងនៅចំពោះមុខមនុស្សដ៏ច្រើន។មេរៀនដ៏មានតម្លៃទាំងនេះត្រូវបានរៀនតាមរយៈកម្មវិធីនេះជាមួយនឹងការធ្វើការងារជាក្រុមនិងសហប្រតិបត្តិការណ៍ដែលជាស្នូលនៃវគ្គរៀននិមួយៗ។យើងខ្ញុំសង្ឃឹមថានឹងរួមសហប្រតិបត្តិការជាមួយនឹង STOMP រហូតដល់ចុងត្រីមាសទី៣។ពេលរៀននឹងចាប់ផ្តើមនៅថ្ងៃទី២៤/៧នៅសាខាខាងលិច,ទី២៥/៧នៅសាខាវ៉ាល្លី។

## ការស្ទង់មតិពីមាតាបិតា:

ការស្ទង់មតិប្រចាំឆ្នាំពីក្រសួងអប់រំនឹងចាប់ផ្តើមនៅពេលឆាប់ៗនេះសំរាប់គ្រួសារមួយចំនួនតាមការជ្រើសរើសព្រាវដើម្បីឆ្លើយតបនឹងសំណួរខ្លះទាក់ទងទៅនឹងយោបល់របស់មាតាបិតាចំពោះវិស័យនានានៃសាលាយើង។បើលោកអ្នកបានជ្រើសរើស,លោកអ្នកនឹងបានទទួលសំបុត្រមួយដែលក្នុងនោះមានតំណនាំទៅដល់សំណួរនៃការស្ទង់មតិដែលអាចបំពេញតាមរយៈទូរស័ព្ទចល័តដែលលោកអ្នកកំពុងប្រើ។ចម្លើយទាំងឡាយនឹងបានចាត់ទុកជាអនាមិក,យកឲ្យក្រុមប្រឹក្សាសាលាមើលមុនគេ,បន្ទាប់មកគឺផ្សាយក្នុងប័ណ្ណព័ត៌មានសាលា។
បើលោកអ្នកបានសាលាចាប់ត្រូវឈ្មោះ,សូមមេត្តាទុកពេលឆ្លើយនឹងសំណួរ។លោកអ្នកអាចជ្រើសរើសភាសាតាមត្រូវការនៅក្នុងតំណនេះ។
បើត្រូវការជំនួយក្នុងការបំពេញ,សូមទាក់ទងនឹងការិយាល័យ,បុគ្គលិករីករាយនឹងជួយជូន។

**សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : Food Bank,Ardoch,Woodleigh School, OSH Club,Berry Street,Ed Connect**

## *កម្មវិធីឆ្កែស្និទ្ធស្នាល:*

*ត្រីមាសនេះ,កម្មវិធីឆ្កែស្និទ្ធស្នាលនឹងត្រឡប់មកម្តងទៀត,តែម្តងនេះនឹងប្រព្រឹត្តទៅឡើងនៅសាខាខាងលិច។ពុំមែនកុមារគ្រប់រូបអាចមានឱកាសចូលរួមក្នុងការជួបនឹង* Leah *ហើយនឹងឆ្កែរបស់គាត់ឈ្មោះ* Scout *នៅបណ្ណាល័យឡើយ,តែកុមារគ្រប់គ្នានឹងបានឃើញឆ្កែខុសគ្នាមកលេងក្នុងថ្នាក់រៀនរបស់កុមារដើម្បីអង្អែលលេង។ សូមអរគុណ*Mrs Harry *ដែលបានចាត់ចែងកម្មវិធីដ៏ប្រសើរនេះដែលនឹងមានដំណើរការរហូតដល់ចុងត្រីមាសទី៣។*

## *ថ្ងៃគំរោងកម្មវិធីសិក្សាត្រីមាសទី៣:*

*ចំពោះគ្រួសារដែលត្រូវរៀបចំចាត់ចែងមើលកូនចៅនៅផ្ទះ,យើងខ្ញុំសូមជំរាបថាសាលានឹងមានការរៀនសូត្របំប៉នវិជ្ជាជីវៈជាមួយនឹង* Berry Street *នៅថ្ងៃអង្គារទី២៩/៨។បុគ្គលិកសាលាទាំងឡាយនឹងចូលរួមទាំងអស់គ្នាក្នុងថ្ងៃនេះ។*

*សូមឲ្យពិរសប្តាហ៍ទៅមុខនេះប្រកកបដោយក្តីសុខនិងសប្បាយ*

Julie Fisher : *នាយកសាលា*

## *ក្តារផ្សាយពត៌មានអំពីរាត្រីជូនដំណឹងសំរាប់ថ្នាក់មូលដ្ឋាន២០២៤*

*សូមថ្លែងអំណរអរគុណដល់អាឡុក-ប៉ូដែល* (Alok Paudel *មកពីក្រុមហ៊ុនអចលនទ្រព្យ* Harcourts *ចំពោះការរចនាផ្ទាំងផ្សាយពត៌មានសំរាប់រាត្រីជូនដំណឹងដល់ថ្នាក់មូលដ្ឋានឆ្នាំ២០២៤,ហើយដែលបានដាក់តាំងនៅមុខសាខាខាងលិចនិងវ៉ាល្លីរបស់យើង។ លោកប៉ូដែល,ជាមាតាបិតាម្នាក់នៃសិស្សសាលាយើងនៅសាខាខាងលិច,ហើយយើងសូមថ្លែងអំណរអរគុណជាខ្លាំងដល់ក្រុមហ៊ុនរបស់លោកដែលអាចរចនានិងផលិតក្តារទាំងនេះសំរាប់យើងខ្ញុំ។ ផ្ទាំងពត៌មាននេះពិតជាភ្លឺហើយទាក់ភ្នែក!*




## *បង្គោលទង់ជាតិថ្មី*

*នៅពេលវិស្សមកាលខែមិថុនា,យើងខ្ញុំបានតម្លើងបង្គោលទង់ជាតិចំនួន៨-២នៅសាខានិមួយៗ ដូច្នេះសាលាអាចបង្ហើរទង់ជាតិនៃជនជាតិដើមភាគតិច,ជនជាតិកោះ,ជាមួយនឹងទង់ជាតិអូស្រ្តាលី។យើងខ្ញុំសូមអរគណាំសមាជិកនៃយុវក្រុមប្រឹក្សាសាលាដែលបានសរសេរសំបុត្រទៅការិយាល័យតំណាងរាស្រ្ត* Claire O’Neill *ហើយសំណូមពរអំណោយទង់ជាតិថ្មីចំនួន៨។ ទង់ជាតិទាំង៨នេះក៏បានមកដល់សាលានៅត្រីមាសមុន,ហើយបានបង្ហាញខ្លួននៅសប្តាហ៍មុន។ តម្លៃសារុបនៃគំរោងការណ៏នេះគឺ$៨,២០០,ហើយសាលាអាចគ្របគ្រងប្រាក់ចំណាយទាំងនេះតាមរយៈអំណោយសប្បុរសធម៌ពីគ្រួសារទៅឲ្យមូលនិធិសំណង់($១,៦៣៨)មូលនិធិសម្លេងសិស្ស($១,៧៥០) និងមូលនិធិវៃប្រាក់ ($១,០២៨)។*



# រាត្រីជូនដំណឹងដល់គ្រួសារថ្នាក់មូលដ្ឋានឆ្នាំសិក្សា២០២៤

## ថ្ងៃទី ៣០ សីហា ម៉ោង ៦:៣០ល្ងាច នៅសាខាខាងលិច

នៅពេលជូនដំណឹងនេះ,យើងខ្ញុំនឹងប្រាប់ជូនលោកអ្នកថា

តើសាលានឹងផ្តល់ឲ្យកូនលោកអ្នកនូវអ្វីខ្លះ ?



## ថ្ងៃទី១៧- ខែ វិច្ឆិការ-២០២៣

## វេលាម៉ោង ៧:០០យប់ នៅសាខាវ៉ាល្លី

នៅពេលជូនដំណឹងនេះ,យើងខ្ញុំនឹងប្រាប់ជូនលោកអ្នករបៀបរៀបចំឲ្យកុមារចាប់ផ្តើមមកសាលារៀន។

**Spring Parks Primary School- West Campus**
24 Erica Street,
Springvale
9546 6402

កម្មវិធីផ្លាស់ប្តូរថ្នាក់សំរាប់ឲ្យកុមារមករួម:
(ឲ្យកុមារមកស្គាល់មិត្ត,សាលានិងគ្រូថ្មី
(ពេលមករួមទាំងឡាយនឹងប្រព្រឹត្តទ្បើងនៅថ្ងៃសុក្រពីម៉ោង៩០០ព្រឹក-១០:០០ព្រឹក)
លើកទី១: ថ្ងៃទី៣/១១/២០២៣
លើកទី២: ថ្ងៃទី១០/១១/២០២៣
លើកទី៣: ថ្ងៃទី១៧/១១/២០២៣

**Spring Parks Primary School- Valley Campus**
27-39 Clarke Road,
Springvale South.
9547 3222

លោកអ្នកអាចចុះឈ្មោះឲ្យកុមារមករួមតាមរយៈអ៊ីម៉ែល។

**ពេលប្រជុំទាំងឡាយនឹងប្រព្រឹត្តទ្បើងនៅសាខាទាំងពីរ.**

Kim.Ary@education.vic.gov.au

**https://springparksps.vic.edu.au/**

# ១០០ថ្ងៃរៀននៅសាលា

នាថ្ងៃសុក្រទី១៨/៧,សាលាទាំងមូលបានមកជួបជុំគ្នានៅសាខាវ៉ាល្លី ដើម្បីប្រារព្ធ១០០ថ្ងៃរៀននៅសាលាឆ្នាំ២០២៣។ជាព្រឹត្តិការមួយអស្ចារ្យណាស់ដែលបានឃើញគ្រូនិងសិស្សស្លៀកពាក់យ៉ាងស្អាតស្អំ-តុបតែងខ្លួនជាអ្វីម្យ៉ាង-តំណាងលេខ១០០។កុមាររីករាយក្នុងការចូលរួមគ្នាក្នុងសកម្មភាពដ៏រីករាយនានាដែលមានលំនាំទាក់ទងនឹងគណិតសាស្រ្ត។ មានសកម្មភាពខ្លះ:ទាក់ទងនឹងរាងកាយ,សិល្បៈ-ហត្ថកម្ម-រចនា,បច្ចេកទេស,កំណាព្យ-តន្ត្រី,ល្បែងហើយនឹងចំណីអាហារ។

នៅពេលគោរពទង់ជាតិ,កុមារបានរួតសម្លៀកបំពាក់ដ៏ឆ្នើមរបស់ខ្លួន, ហើយទទួលបទពិសោធន៏នឹងមេរៀនខ្លាតតូចអំពីការរៀនប្រមាណក្នុងការលេងចាប់ឆ្នោត។មានកុមារមួយចំនួនមកពីថ្នាក់រៀននិមួយៗនៃសាខាទាំងពីរមានសំណាងដោយបានជ័យជំនះក្នុងការលេងល្បែងលើក្តារ(លេងអុក,ប្រណាំងសេះលើក្រដាស់ជាដើម)។ជាការល្អប្រសើរណាស់ដែលបានឃើញញសមាជិកគ្រួសារអាចមកហើយចូលរួមក្នុងការលេងដ៏សប្បាយ។សូមអរគុណអ្នករាល់គ្នាដែលបានធ្វើឲ្យថ្ងៃនេះជាថ្ងៃដ៏ពិសេសមួយ។













